## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០១៣

## ជប៉ុនផ្តល់ ២០៤,៨៩៩ ដុល្លារអាមេរិក សម្រាប់គម្រោងស្តារប្រព័ន្ធធារាសាស្ត្រ ក្នុងខេត្តកំពង់ចាម និងខេត្តពោធិ៍សាត់



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន (ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន២០៤,៨៩៩ ដុល្លារអាមេរិក ដល់មន្ទីរធនធានទឹក និងឧតុនិយមចំនួន២។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងតំណាងស្ថាប័នទទួលជំនួយទាំង២សម្រាប់គម្រោងដូចតទៅ៖

១. <u>គម្រោងស្តារប្រព័ន្ធធារាសាស្ត្រដូង ខេត្តកំពង់ចាម (៩៤,៨៩១ដុល្លារអាមេរិក)</u>

<u>ស្ថាប័នទទួលជំនួយ៖ មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ចាម</u>

គម្រោងនេះគឺដើម្បីស្តារទំនប់ប្រវែង៧៥០ម៉ែត្រ ជួសជុលសំណង់បញ្ចូលទឹកមួយកន្លែង និងសំណង់បញ្ចេញទឹកមួយកន្លែង សាងសង់សំណង់បញ្ចូលទឹកមួយកន្លែង និងសំណង់បញ្ចេញទឹកពីរកន្លែង។ យើងសង្ឃឹមថាគម្រោងនេះនឹងកាត់បន្ថយផលប៉ះពាល់ពីទឹកជំនន់ប្រចាំឆ្នាំ ព្រមទាំងជួយសម្រួលដល់ការទទួលបានទឹកស្រោចស្រពសម្រាប់ដីស្រែរបស់ប្រជាជនប្រមាណ៧៥០គ្រួសារក្នុងតំបន់។



កម្ពស់ទំនប់ទាប(ប្រព័ន្ធធារាសាស្ត្រដូង)

២. <u>គម្រោងស្តារប្រព័ន្ធធារាសាស្ត្រកំពែង ខេត្តពោធិ៍សាត់ (ដំណាក់កាលទី២) (១១០,០០៨ដុល្លារអាមេរិក)</u>

<u>ស្ថាប័នទទួលជំនួយ៖ មន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់</u>



ផ្លូវទឹកនៅសម័យប៉ុលពត (ប្រព័ន្ធធារាសាស្ត្រកំពែង)

គម្រោងនេះគឺដើម្បីស្តារប្រឡាយរងប្រវែង២,៥៥០ម៉ែត្រ ជួសជុលសំណង់បញ្ចូលទឹកមួយកន្លែង និងសាងសង់លូប្រអប់មួយកន្លែង សំណង់ស្ទាក់ទឹកពីរកន្លែង និងសំណង់បញ្ចេញទឹកបួនកន្លែង។ យើងសង្ឃឹមថាគម្រោងនេះនឹងជួយកាត់បន្ថយផលប៉ះពាល់ពីទឹកជំនន់ប្រចាំឆ្នាំ ព្រមទាំងសម្រួលដល់ការទទួលបានទឹកស្រោចស្រពដីស្រែសម្រាប់ប្រជាជនប្រមាណ៥០០គ្រួសារក្នុងតំបន់។

ជាមួយនឹងជំនួយបច្ចេកទេសពីមន្ទីរនិមួយៗ ប្រជាសហគមន៍ក្នុងតំបន់គោលដៅនឹងថែទាំប្រព័ន្ធធារាសាស្ត្រទាំងពីរនេះឲ្យបានល្អប្រសើរ។

ជំនួយ *គូសាណូណេ* របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជុំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥០.១ លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៥០១ គម្រោងនៅទូទាំងប្រទេស។



*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីមែល: eco.jpn@.pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*